ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ

លេខ : ១៣៨៤ សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការប្រគល់សិទ្ធិជូនរដ្ឋលេខាធិការក្រសួងមហាផ្ទៃ ពិនិត្យ សម្រេច និងចុះហត្ថលេខាជួសរដ្ឋមន្ត្រី

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃក្រសួងមហាផ្ទៃ
- បានឃើញសេចក្តីសម្រេចលេខ ០០១ សសរ ចុះថ្ងៃទី ១៥ ខែ តុលា ឆ្នាំ២០០៨ ស្តីពីរបៀបរបបការងារ និងបែងចែកភារកិច្ច របស់ថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ

## សម្រេច

**ប្រការ ១** : ត្រូវបានប្រគល់សិទ្ធិជូនរដ្ឋលេខាធិការក្រសួងមហាផ្ទៃ ក្នុងការពិនិត្យ សម្រេច ព្រមទាំងការចុះហត្ថលេខាជួសរដ្ឋមន្ត្រី នូវកិច្ចការមួយចំនួន ដូចខាងក្រោម :

**១-ឯកឧត្តម ឯម សំអាន :**

- ពិនិត្យលើការងារដែលទាក់ទិននឹងការទទួលស្គាល់ជនបរទេសអន្តោប្រវេសន្ត ដែលបានពិនិត្យចុះបញ្ជីរួចនៅតាមបណ្តាខេត្ត រាជធានី ដើម្បីដាក់ជូនរដ្ឋរដ្ឋមន្ត្រីពិនិត្យ និងសម្រេច
- ពិនិត្យ និងចុះហត្ថលេខាលើការបណ្តេញជនជាតិបរទេសចេញពីកម្ពុជា ក្រោយមានគោលការណ៍សម្រេចពីរដ្ឋមន្ត្រី

- ពិនិត្យ សម្រេច និងចុះហត្ថលេខា ចាត់បញ្ជូនមន្ត្រីនគរបាលជាតិ ចូលរួមវគ្គបណ្តុះបណ្តាលវគ្គសិក្សា ចុះបំពេញបេសកកម្មនៅបរទេស ចាប់ពីថ្នាក់ប្រធានការិយាល័យចុះ
- ពិនិត្យ សម្រេច និងចុះហត្ថលេខា ចាត់បញ្ជូនមន្ត្រីនគរបាលជាតិ ចូលរួមបណ្តុះបណ្តាលវគ្គសិក្សា ចុះបំពេញបេសកកម្មនៅក្នុងប្រទេស ចាប់ពីថ្នាក់អនុរដ្ឋលេខាធិការចុះ
- ពិនិត្យ និងសម្រេចលើសំណើសុំថវិកា ប្រេងឥន្ធនៈ សម្រាប់ចុះបេសកកម្មក្នុងប្រទេស ផ្នែកនគរបាលជាតិ សម្រាប់ករណីមួយលើកៗ ។

**២-ឯកឧត្តម ញ៉ាំ សុខា :**

- ពិនិត្យ សម្រេច និងចុះហត្ថលេខា ចាត់បញ្ជូនមន្ត្រីរដ្ឋបាលស៊ីវិលចូលរួមវគ្គបណ្តុះបណ្តាល វគ្គសិក្សា ចុះបេសកកម្មនៅបរទេស ចាប់ពីថ្នាក់ប្រធានការិយាល័យចុះ
- ពិនិត្យ សម្រេច និងចុះហត្ថលេខា ចាត់បញ្ជូនមន្ត្រីរដ្ឋបាលស៊ីវិលចូលរួមវគ្គបណ្តុះបណ្តាល វគ្គសិក្សា ចុះបំពេញបេសកកម្មនៅក្នុងប្រទេស ចាប់ពីថ្នាក់អនុរដ្ឋលេខាធិការចុះ
- ពិនិត្យ និងសម្រេចក្នុងការចាត់បញ្ជូនមន្ត្រីចូលរួមប្រជុំ សិក្ខាសាលា តាមការអញ្ជើញរបស់ក្រសួង ស្ថាប័ននានា ចាប់ពីថ្នាក់អនុរដ្ឋលេខាធិការចុះ ( រួមទាំងកិច្ចការដែលពាក់ព័ន្ធនឹងផ្នែកនគរបាល និងរដ្ឋបាលស៊ីវិល )
- ពិនិត្យ និងសម្រេចលើសំណើសុំថវិកា ប្រេងឥន្ធនៈ សម្រាប់បេសកកម្មក្នុងប្រទេស ផ្នែករដ្ឋបាលស៊ីវិល សម្រាប់ករណីមួយលើកៗ ។

**៣-ឯកឧត្តម នុត សាវអាន :**

- ពិនិត្យ សម្រេច និងចុះហត្ថលេខា រាល់ឯកសារពាក់ព័ន្ធនឹងការងារពន្ធនាគារ ព្រមទាំងឯកសារទាក់ទងនឹងការស្នើសុំបង្កើតអង្គការ និងសមាគម ។

**៤-ឯកឧត្តម សក់ សេដ្ឋា :**

- ពិនិត្យ សម្រេច និងចុះហត្ថលេខា ឯកសាររបស់ គ.ជ.អ.ប ក្រោយពីមានការសម្រេចពីឯកឧត្តមឧបនាយករដ្ឋមន្ត្រី ។

**៥-ឯកឧត្តម ប៉ុល លឹម :**

- ពិនិត្យ និងចុះហត្ថលេខា លើលិខិតស្នាមដែលពាក់ព័ន្ធនឹងការប្តឹងតវ៉ា បណ្តឹងបរិហារនានា ក្រោយពីមានគោលការណ៍សម្រេចពីរដ្ឋមន្ត្រី ។

**៦-លោកជំទាវ ជូ ប៊ុនអេង :**

- ពិនិត្យ និងចុះហត្ថលេខា លើឯកសារពាក់ព័ន្ធនឹងការស្នើសុំរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស ។

**៧-ឯកឧត្តម ទី ចំរុងផល :**

- ពិនិត្យ សម្រេច និងចុះហត្ថលេខា លើឯកសារដែលពាក់ព័ន្ធនឹងគម្រោងមូលនិធិ ដែលទទួលបានពីធនាគារពិភពលោក និងធនាគារអភិវឌ្ឍន៍អាស៊ី ក្រោយពីមានគោលការណ៍សម្រេចពីរដ្ឋមន្ត្រី ។

**ប្រការ ២** ៖ ឯកឧត្តមរដ្ឋលេខាធិការ ដែលត្រូវចុះហត្ថលេខាលើឯកសារ ដូចមានចែងក្នុងប្រការ១ បើពិនិត្យឃើញ មានលក្ខណៈស្មុគ្រស្មាញ ហួសសមត្ថកិច្ច ត្រូវរាយការណ៍ និងសុំគោលការណ៍បន្ថែមពីរដ្ឋមន្ត្រី ។

- បំពេញភារកិច្ចផ្សេងទៀត ទៅតាមការប្រគល់ជូនរបស់រដ្ឋមន្ត្រី ។

**ប្រការ ៣** ៖ អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន អគ្គស្នងការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន អគ្គនាយក នៃអគ្គនាយកដ្ឋានភស្តុភារនិងហិរញ្ញវត្ថុ អគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធនាគារ អគ្គាធិការ នៃអគ្គាធិការដ្ឋានកិច្ចការនយោបាយ រដ្ឋបាល និងនគរបាល ប្រធានបណ្ឌិតសភានគរបាលកម្ពុជា ប្រធានក្រុមប្រឹក្សានីតិកម្ម ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង និងឯកឧត្តម លោកជំទាវ ដែលមានឈ្មោះខាងលើត្រូវអនុវត្តសេចក្ដីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ មិនា ឆ្នាំ ២០១០*

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**កន្លែងទទួល** ៖

- *ទីស្ដីការគណៈរដ្ឋមន្ត្រី*
- *ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ*
- *ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឯកឧត្ដម **ស ខេង** ឧបនាយករដ្ឋមន្ត្រី*
- *ដូចប្រការ១ និងប្រការ៣*
- *ឯកសារ - កាលប្បវត្តិ*